**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៩៤
ចុះថ្ងៃទី១៥-មិថុនា-២០២២
សាលក្រមលេខ: **២៨ (ន)**
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង១១ និង០០នាទីព្រឹក លើសំណុំរដ្ឋប្បវេណីលេខ: ៤៩៤ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] **ទណ្ឌា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជី**

-លោក [redacted] **អ៊ាន់ឌី** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**គូភាគីជាអាទិ៍៖**

**-<u>រវាងដើមចោទ</u>**៖ ឈ្មោះ [redacted] ថាច ភេទប្រុស អាយុ៤៧ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted] បច្ចុប្បន្នរស់នៅ [redacted]។

**-អ្នកតំណាងដោយអាណត្តិ**៖ លោកមេធាវី [redacted] អត្តលេខ៨០២ **ការិយាល័យមេធាវី** [redacted]។

**-<u>និងចុងចម្លើយ</u>**៖ ឈ្មោះ [redacted] សារី ហៅ [redacted] សារី ភេទស្រី កើតឆ្នាំ១៩៦១ សញ្ជាតិខ្មែរ និងប្ដីឈ្មោះ [redacted] ហាវឿន ភេទប្រុស កើតឆ្នាំ១៩៦៣ ទីលំនៅបច្ចុប្បន្ន [redacted]

-អ្នកតំណាងដោយអាណត្តិ៖ លោកមេធាវី [redacted] អត្តលេខ២៥២៨T និងលោកមេធាវី [redacted] អត្តលេខ២៦១៣T **ក្រុមហ៊ុនមេធាវី** [redacted]។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

ប្ដឹងសុំឱ្យសាលាដំបូងខេត្តកណ្ដាលចេញសាលក្រមដូចខាងក្រោម៖

១.១- បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] ថាច ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុផ្ទះ និងដី ទំហំ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] វុន មានទីតាំងស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល។

១.២- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សារី ហៅ [redacted] សារី ប្រគល់អចលនវត្ថុផ្ទះ និងដីទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] វុន មានទីតាំងស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល ឱ្យមកដើមចោទឈ្មោះ [redacted] ថាច។

១.៣- សុំទាមទារសំណងការខូចខាត សេវាកម្មច្បាប់ និងសំណងជម្ងឺចិត្តចំនួន ៥០.០០០$ (ប្រាំម៉ឺនដុល្លារអាមេរិច)។

១.៤- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។



Scanned with CamScanner

២- ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ៖

ប្ដឹងសុំឱ្យសាលាដំបូងខេត្តកណ្ដាលចេញសាលក្រមដូចខាងក្រោម៖

២.១- ច្រានចោលពាក្យបណ្ដឹង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] ថាច ចោលជាអសារបង់។

២.២- សុំឱ្យធ្វើនីតិវិធីចុះបញ្ជីវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលមានក្បាលដីលេខ៖ ៣១៨ ស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល ពីឈ្មោះ [redacted] ថាច មកឱ្យឈ្មោះ [redacted] សារី និងឈ្មោះ [redacted] សារឿន ជាម្ចាស់កម្មសិទ្ធិវិញ។

២.៣- សុំទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តចំនួន ៥០.០០០$ (ប្រាំម៉ឺនដុល្លាអាមេរិច)។

២.៤- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

៣- ការពន្យល់ត្រួសៗអំពីរឿងក្ដី៖

កាលអំឡុងឆ្នាំ ១៩៩៩ ម្ដាយរបស់ដើមចោទឈ្មោះ [redacted] នឿន កាលគាត់នៅរស់គាត់បានធ្វើប្រទានកម្មដីទំហំ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ ជូនដើមចោទឈ្មោះ [redacted] ថាច ដែលមានទីតាំងដីស្ថិតនៅភូមិកណ្ដាលកោះ ឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្ដាល។ ពេលទទួលដីពីម្ដាយ ដើមចោទបាទក៏បានដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លី ដែលមានការទទួលស្គាល់ពីអាជ្ញាធរឃុំត្រឹមត្រូវតាមច្បាប់ និងបានដាក់ឯកសារនេះចូលទៅកាន់ការិយាល័យភូមិបាលស្រុងស្អាងតាមនីតិវិធីច្បាប់។ នៅពេលម្ដាយរបស់ដើមចោទនៅរស់គាត់មានជំងឺធ្ងន់ធ្ងរ ហើយដើមចោទនឹងត្រូវចេញទៅធ្វើការនៅប្រទេសបារាំងទៀត នៅសល់តែចុងចម្លើយត្រូវមើលថែទាំម្ដាយស្រាប់តែចុងចម្លើយបានចុះចេញពីផ្ទះទៅរស់នៅកន្លែងផ្សេងទុកម្ដាយចោល ដោយមិនបានមើលថែគាត់ឡើយទើបនៅពេលនោះម្ដាយដើមចោទបានសម្រេចលុបឈ្មោះចុងចម្លើយចេញពីបញ្ជីគ្រួសារថែមទៀត។ ក្រោយមកចុងចម្លើយពុំមានកន្លែងស្នាក់នៅក៏បានមកសុំដើមចោទស្នាក់នៅលើផ្ទះ និងដីជាបណ្ដោះអាសន្ន ដោយចិត្តអាណិតចុងចម្លើយ ទើបដើមចោទយល់ព្រមឱ្យចុងចម្លើយស្នាក់នៅ មើលថែរក្សាផ្ទះ និងដីជាបណ្ដោះអាសន្ន។

បន្ទាប់មកនៅក្នុងអំឡុងឆ្នាំ២០២០ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្ដាលបានចុះមកធ្វើការវាស់វែងដីធ្លី ដើម្បីរៀបចំចុះបញ្ជីកម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជាប្រព័ន្ធជូនប្រជាពលរដ្ឋ ដែលមានដីស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល។ ពេលនោះដើមចោទបានត្រឡប់មកពីប្រទេសបារាំងវិញ ដើម្បីរៀបចំបំពេញឯកសារស្នើសុំចុះបញ្ជីកម្មសិទ្ធិនេះ។ បន្ទាប់ពីរៀបចំឯកសារនេះរួច មន្ត្រីសុរិយោដីបានធ្វើការពិនិត្យឯកសារ និងបានចុះវាស់វែងដីរបស់ដើមចោទរួចហើយ មន្ត្រីសុរិយោដីបានចេញបង្កាន់ដីលេខ ០៨១១០៨០២០៥៤៥ ក្បាលដីលេខ ០៣១៨ ជូនដើមចោទ។ ពេលទទួលបានឯកសារបង្កាន់ដៃនេះហើយដើមចោទក៏ដល់ពេលទៅប្រទេសបារាំងវិញ។ ប៉ុន្តែពេលដែលដើមចោទត្រឡប់ទៅប្រទេសបារាំងវិញស្រាប់តែចុងចម្លើយប្ដឹងជំទាស់ទៅលើក្បាលដីរបស់ដើមចោទ ដោយអះអាងថា ដីនេះជាកម្មសិទ្ធិរបស់ខ្លួន និងលើកយកឯកសារពាក្យស្នើសុំកាន់កាប់ដីធ្លី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩០ មកធ្វើការអះអាងសិទ្ធិទាំងដែលពាក្យស្នើសុំកាន់កាប់ដីធ្លីនេះត្រូវបាននិរាករណ៍ ឬ បដិសេធចោលហើយ ព្រោះពាក្យស្នើសុំកាន់កាប់ដីធ្លីនេះ ចុងចម្លើយបានលួចទៅធ្វើតាំងពីម្ដាយនៅរស់ មិនឱ្យម្ដាយដឹងឡើយតែនៅពេលម្ដាយដើមចោទបានដឹងបែបនេះ គាត់ក៏បានសើរើ និងទៅដោះស្រាយនៅសាលាឃុំ ដោយសារតែមិនចង់ឱ្យដើមចោទ និងចុងចម្លើយឈ្លោះគ្នា ម្ដាយរបស់ដើមចោទបានទិញដីចំនួនពីរកន្លែងស្ថិតនៅភូមិកណ្ដាលកោះនេះដែរ ដើម្បីចែកឱ្យចុងចម្លើយជំនួសដីខាងលើនេះវិញ ដោយបានធ្វើលិខិតប្រទានកម្ម ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ នៅចំពោះមុខអាជ្ញាធរឃុំឱ្យដឹងឮ និងទទួលស្គាល់ផងដែរ។ តាមរយៈនេះហើយទើបពាក្យស្នើសុំកាន់កាប់ដីធ្លីត្រូវបានអាជ្ញាធរឃុំនិរាករណ៍ ឬ បដិសេធចោលវិញ។ម្យ៉ាងវិញទៀត ចៅសង្កាត់កោះអន្លង់ចិនក៏បានបញ្ជាក់ផងដែរថា ដីដែលជាកម្មវត្ថុខាងលើនេះជារបស់កម្មសិទ្ធិរបស់ដើមចោទ។



Scanned with CamScanner

## សេចក្តីថ្លែងការណ៍របស់គូភាគី

**៤- ការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖**

**អ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖** សុំរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២៖

ក. បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] ថាច ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុផ្ទះ និងដី ទំហំ១.៦១៦ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] រុន មានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

ខ. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សារី ហៅ [redacted] សារី ប្រគល់អចលនវត្ថុផ្ទះ និងដី ទំហំ១.៦១៦ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] រុន មានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ឱ្យមកដើមចោទឈ្មោះ [redacted] ថាច។

គ. សុំទាមទារសំណងការខូចខាត សេវាកម្មច្បាប់ និងសំណងជម្ងឺចិត្ត ចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិច)។

ឃ. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ដោយអះអាងថា:** កាលពីអំឡុងឆ្នាំ១៩៩៩ ម្តាយរបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] នឿន កាលគាត់នៅរស់គាត់បានធ្វើប្រទានកម្មដីទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ ជូនកូនក្តីខ្ញុំបាទឈ្មោះ [redacted] ថាច ដែលមានទីតាំងស្ថិតនៅភូមិកណ្តាលកោះ ឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល)។ ពេលទទួលបានដីពីម្តាយ កូនក្តីខ្ញុំបាទក៏បានដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លី ដែលមានការទទួលស្គាល់ពីអាជ្ញាធរឃុំត្រឹមត្រូវតាមច្បាប់ និងបានដាក់ឯកសារនេះចូលទៅកាន់ការិយាល័យភូមិបាលស្រុកស្អាងតាមនីតិវិធីច្បាប់។ កាលម្តាយរបស់កូនក្តីខ្ញុំបាទគាត់នៅរស់គាត់មានជម្ងឺធ្ងន់ធ្ងរ ហើយកូនក្តីខ្ញុំបាទត្រូវចេញទៅធ្វើការនៅប្រទេសបារាំងទៀត នៅសល់តែចុងចម្លើយត្រូវមើលថែម្តាយកំពុងមានជម្ងឺ ស្រាប់តែចុងចម្លើយបានចុះចេញពីផ្ទះទៅរស់នៅកន្លែងផ្សេង ទុកម្តាយចោលមិនបានមើលថែគាត់ឡើយ ទើបនៅពេលនោះម្តាយរបស់កូនក្តីខ្ញុំបាទសម្រេចលុបឈ្មោះចុងម្លើយចេញពីបញ្ជីគ្រួសារថែមទៀតផង។ ក្រោយមកបងស្រីបង្កើតរបស់កូនក្តីខ្លួនឈ្មោះ [redacted] សារី ហៅ [redacted] សារី ពុំមានកន្លែងស្នាក់នៅ ក៏បានសុំកូនក្តីខ្ញុំបាទស្នាក់នៅលើផ្ទះ និងដីនេះជាបណ្តោះអាសន្ន ព្រោះខ្លួនមិនមានកន្លែងរស់នៅ ហេតុតែកូនក្តីខ្ញុំបាទអាណិតបងស្រីក៏យល់ព្រមឱ្យឈ្មោះ [redacted] សារី ហៅ [redacted] សារី ស្នាក់នៅ និងមើលថែរក្សាផ្ទះ និងដី ជាបណ្តោះអាសន្នសិន ចាប់តាំងពីពេលនោះមកឈ្មោះ [redacted] សារី ហៅ [redacted] សារី ស្នាក់នៅរហូតដល់ពេលបច្ចុប្បន្ននេះ។

បន្ទាប់មកអំឡុងឆ្នាំ២០១៩ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល បានចុះមកធ្វើការវាស់វែងដីធ្លី ដើម្បីរៀបចំចុះបញ្ជីកម្មសិទ្ធិ និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជាប្រព័ន្ធជូនដល់ប្រជាពលរដ្ឋ ដែលមានដីស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។ ពេលនោះកូនក្តីខ្ញុំបាទបានត្រលប់មកពីប្រទេសបារាំង ដើម្បីរៀបចំបំពេញឯកសារស្នើសុំចុះបញ្ជីកម្មសិទ្ធិនេះដែរ។ បន្ទាប់ពីរៀបចំឯកសាររួច មន្ត្រីសុរិយោដីបានធ្វើការពិនិត្យឯកសារ និងបានចុះវាស់វែងដីរបស់កូនក្តីខ្ញុំបាទរួចហើយមន្ត្រីសុរិយោដីបានចេញបង្កាន់ដីលេខ ០៨១១០៨០២០៥៤៥ ក្បាលដីលេខ: ០៣១៨ ជូនកូនក្តីខ្ញុំបាទ។ ពេលទទួលបានឯកសារបង្កាន់ដៃនេះហើយ កូនក្តីខ្ញុំបាទក៏បានដល់ពេលត្រលប់ទៅប្រទេសបារាំងវិញ។ ប៉ុន្តែពេលដែលកូនក្តីខ្ញុំបាទត្រលប់ទៅដល់ប្រទេសបារាំងវិញ ស្រាប់តែបងស្រីបង្កើតឈ្មោះ [redacted] សារី ហៅ [redacted] សារី ប្តឹងជំទាស់លើក្បាលដីរបស់



Scanned with CamScanner

កូនក្តីខ្ញុំបាទទៅវិញ ដោយឈ្មោះ[redacted]សារី ហៅ[redacted] សារី បានអះអាងថា ដីនេះជាកម្មសិទ្ធិរបស់ខ្លួន។ ដោយឈ្មោះ[redacted] សារី ហៅ[redacted]សារី លើកយកឯកសារពាក្យស្នើសុំកាន់កាប់ដីធ្លី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩០ មកធ្វើការអះអាងសិទ្ធិទាំងដែលពាក្យស្នើសុំកាន់កាប់ដីធ្លីនេះត្រូវបាននិរាករណ៍ ឬ បដិសេធចោលហើយ ព្រោះពាក្យស្នើសុំកាន់កាប់ដីធ្លីនេះឈ្មោះ[redacted]សារី ហៅ[redacted]សារី បានលួចទៅធ្វើលិខិតនេះតាំងពីម្តាយនៅរស់មិនឱ្យម្តាយដឹងឡើយ តែនៅពេលម្តាយរបស់កូនក្តីខ្ញុំបាទបានដឹងបែបនេះ គាត់ក៏បានទៅសើរើ និងដោះស្រាយនៅសាលាឃុំ។ ដោយសារតែមិនចង់ឱ្យកូនៗឈ្លោះគ្នា ម្តាយរបស់កូនក្តីខ្ញុំបាទបានទិញដីពីរកន្លែងស្ថិតនៅភូមិកណ្តាលកោះនេះដែរ ដើម្បីចែកឱ្យឈ្មោះ[redacted]សារី ហៅ[redacted]សារី ជំនួសដីខាងលើនេះវិញ ដោយបានធ្វើលិខិតប្រទានកម្ម ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ នៅចំពោះមុខអាជ្ញាធរឃុំឱ្យដឹងឮ និងទទួលស្គាល់ផងដែរ។ ហេតុនេះទើបពាក្យស្នើសុំកាន់កាប់ដីធ្លីត្រូវបានអាជ្ញាធរឃុំធ្វើការនិរាករណ៍ ឬ បដិសេធចោលវិញ។ ហើយអាជ្ញាធរបច្ចុប្បន្នចៅសង្កាត់កោះអន្លង់ចិន (ពីមុនមេឃុំកោះអន្លង់ចិន) ក៏បានធ្វើការបញ្ជាក់បន្ថែមទៀតដែរថា ដីខាងលើនេះជាកម្មសិទ្ធិស្របច្បាប់របស់កូនក្តីខ្ញុំបាទ។

**អំពីអង្គច្បាប់៖**

ក. យោងបង្កាន់ដៃទទួលពាក្យលេខ: ០៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩។

ខ. យោងពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ទទួលស្គាល់ដោយលោក[redacted] ភឿន មេឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នក្រុងតាខ្មៅ ខេត្តកណ្តាល)។

គ. យោងលិខិតបញ្ជាក់លេខ: ២៧៧/១៩ ប ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ទទួលស្គាល់ដោយលោកចៅសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

ឃ. យោងបង្កាន់ដៃស្នើសុំចុះបញ្ជីលេខ: ០៨១១០៨០២០៣១៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩។

ង. យោងតាមឯកសារភស្តុតាងខាងលើ អាចបញ្ជាក់បានថា អង្គហេតុខាងលើគឺជាអង្គហេតុពិតប្រាកដ ហើយកូនក្តីខ្ញុំបាទពិតជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុផ្ទះ និង(ដី) ទំហំ១.៦១៦ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ[redacted] សាខន ខាងលិចទល់នឹងឈ្មោះ[redacted] រុន និងមានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។ ដោយដីនេះគឺកូនក្តីខ្ញុំបាទទទួលបានប្រទានកម្មពីម្តាយឈ្មោះ[redacted]នឿន កាលគាត់នៅរស់។ ហើយឈ្មោះ[redacted]សារី ហៅ[redacted]សារី គ្រាន់តែជាអ្នកមកសុំកូនក្តីខ្ញុំបាទស្នាក់នៅបណ្តោះអាសន្នតែប៉ុណ្ណោះ។

ច. យោងតាមមាត្រា ៥៧០ ប្រទានកម្មដែលមិនធ្វើជាលាយលក្ខណ៍អក្សរ បានចែងថា "ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនមានធ្វើជាលាយលក្ខណ៍អក្សរស្តីពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យា អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន។ ប៉ុន្តែចំពោះផ្នែកដែលបានអនុវត្តហើយ មិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ។"

ផ្អែកតាមមាត្រានេះបានកំណត់ថា ការធ្វើប្រទានកម្មជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់សុទ្ធតែធ្វើទៅបាន។ ហើយការធ្វើប្រទានដី និងផ្ទះខាងលើពីម្តាយកូនក្តីខ្ញុំបាទ មកកូនក្តីខ្ញុំបាទគឺបានធ្វើដោយផ្ទាល់មាត់ ហើយធ្វើនៅចំពោះមុខអាជ្ញាធរឃុំ ទើបអាជ្ញាធរឃុំធ្វើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីជូនកូនក្តីខ្ញុំបាទ ដើម្បីក្លាយជាភោគៈលើដីខាងលើបន្តពីម្តាយ។

ឆ. យោងកិច្ចសន្យាប្រទានកម្មដីពីម្តាយឈ្មោះ[redacted] នឿន ទៅឱ្យកូនឈ្មោះ[redacted]សារី ហៅ[redacted] សារី ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ អាចបញ្ជាក់ថាពាក្យសុំកាន់កាប់ដីធ្លីរបស់ឈ្មោះ[redacted]សារី ហៅ[redacted] សារី គឺឈ្មោះ[redacted] សារី ហៅ[redacted] សារី បានលួចទៅធ្វើទាំងម្តាយមិនបានដឹងឡើយ។ ហើយពាក្យសុំកាន់កាប់ដីធ្លីរបស់ឈ្មោះ[redacted] សារី ហៅ[redacted]សារី ត្រូវបានបដិសេធ និងនិរាករណ៍ ដោយអាជ្ញាធរឃុំរួចរាល់ហើយ។



Scanned with CamScanner

ជ. ការរស់នៅ និងអាស្រ័យផលរបស់ភាគីចុងចម្លើយលើដីវិវាទនេះគឺគ្រាន់តែជាបណ្តោះអាសន្ន ដោយមានការអានិតអាសូរពីភាគីដើមចោទដែលជាម្ចាស់កម្មសិទ្ធិករស្របច្បាប់ក្នុងនាមជាបងប្អូនប៉ុណ្ណោះ។ ហើយម្យ៉ាងទៀតភាគីចុងចម្លើយគ្មានឯកសារផ្លូវច្បាប់ សុពលភាពណាមួយដែលអាចបញ្ជាក់ថាខ្លួនជាកម្មសិទ្ធិករលើដីវិវាទនេះទាំងមូល ឬ មួយផ្នែកណានោះឡើយ។

**សន្និដ្ឋាន៖** យោងតាមអង្គហេតុ និងអង្គច្បាប់ខាងលើបានបញ្ជាក់ថា៖ កូនក្តីរបស់ខ្ញុំបាទពិតជាម្ចាស់កម្មសិទ្ធិលើដីនិងផ្ទះខាងលើនេះពិតប្រាកដមែន។ ហើយឈ្មោះ [redacted] សារី ហៅ[redacted]សារី គ្រាន់តែជាអ្នករស់នៅលើដីកម្មសិទ្ធិរបស់កូនក្តីខ្ញុំបាទជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ ប៉ុន្តែឈ្មោះ[redacted]សារី ហៅ[redacted] សារី មានគំនិតទុច្ចរិតចង់បានដីនេះតាំងពីម្តាយរបស់កូនក្តីខ្ញុំបាទនៅរស់មកម្ល៉េះ។ ដោយពេលនោះពិតណាស់ឈ្មោះ[redacted]សារី ហៅ[redacted]សារី បានលួចទៅធ្វើពាក្យសុំកាន់កាប់ដីធ្លីមិនឲ្យម្តាយដឹងទេ។ ហើយសូម្បីតែបងប្អូនបង្កើតទាំងអស់គេសុទ្ធតែបានដឹងអំពីអត្តចរិតរបស់ឈ្មោះ[redacted] សារី ហៅ[redacted]សារី គឺជាមនុស្សលោភលន់ ហើយឈ្លោះជាមួយបងប្អូនគ្រប់ៗគ្នា។

**៥- ការអះអាងរបស់ចុងចម្លើយ៖**

**ចុងចម្លើយឈ្មោះ [redacted]សារី ហៅ[redacted] សារី បានធ្វើសេចក្តីថ្លែងការណ៍តបថា៖** ដើមចោទឈ្មោះ[redacted] ថាច សុំបញ្ជាក់ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុផ្ទះ និងដី ទំហំ ១៦១០ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ[redacted]សាខន ខាងលិចទល់នឹងឈ្មោះ [redacted]ុន មានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។ នាងខ្ញុំសុំបដិសេធមិនទទួលស្គាល់ថាដីនេះជារបស់ដើមចោទឈ្មោះ[redacted]ថាច ទេ។ **ដោយអះអាងថា:** នាងខ្ញុំបានកាន់កាប់មកតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយនាងខ្ញុំក៏បានរស់នៅជាមួយម្តាយឈ្មោះ[redacted] នឿន និងប្អូនប្រុសឈ្មោះ [redacted] ថាច មករហូត។ ហើយនាងខ្ញុំបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ ដោយមានការយល់ព្រមពីម្តាយ នាងខ្ញុំមិនបានលួចធ្វើពាក្យស្នើសុំនោះទេ។ កាលម្តាយនាងខ្ញុំនៅរស់មិនធ្លាប់បាននិយាយប្រគល់ដី និងផ្ទះ ឬ ទិញដីមកដោះដូរនឹងដីដែលដើមចោទឈ្មោះ[redacted] ថាច សុំទាមទារនោះទេ ដែលដីដោះដូរនោះជាដីអំណោយពីឪពុកក្មេករបស់ខ្លួនទេ។ នាងខ្ញុំរស់នៅជាមួយម្តាយឈ្មោះ[redacted]នឿន នៅលើដី និងផ្ទះទំនាស់នេះរហូតទាល់តែគាត់ស្លាប់ក្នុងអំឡុងឆ្នាំ២០០២។ នាងខ្ញុំមិនបានដឹងថា នៅឆ្នាំ១៩៩៩ ម្តាយធ្វើប្រទានកម្មដី និងផ្ទះទំនាស់នេះឲ្យទៅប្អូនឈ្មោះ [redacted] ថាច នោះទេ។ ផ្ទះចាស់នាងខ្ញុំបានរុះ និងប្អូនឈ្មោះ[redacted] ថាច បានឲ្យប្រាក់មកចំនួន ២៥០០$ (ពីរពាន់ប្រាំរយដុល្លារអាមេរិច) និងលុយចំណែកនាងខ្ញុំចំនួន ៥៥០០$ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិច) មកធ្វើផ្ទះថ្មីលើដីនេះ។ នាងខ្ញុំមិនធ្លាប់បានសុំប្អូនស្នាក់នៅនោះទេ។ ក្នុងអំឡុងឆ្នាំ២០១៩ ប្អូនរបស់ខ្លួនឈ្មោះ[redacted]ថាច បានមកពីប្រទេសបារាំងបានមកវាស់វែង និងធ្វើប័ណ្ណកម្មសិទ្ធិ នាងខ្ញុំមិនទាន់បានដាក់ពាក្យសុំវាស់វែងទេ ដោយគិតថាមិនប៉ះពាល់ដល់ដីរបស់នាងខ្ញុំទេ ប៉ុន្តែពីរសប្តាហ៍ក្រោយមក នាងខ្ញុំបានទៅជំទាស់ដល់សុរិយោដីដើម្បីកុំឲ្យចេញប័ណ្ណជូនប្អូនប្រុសរបស់ខ្លួន។ នៅពេលដែលដោះស្រាយគ្នានៅសាលាឃុំ នាងខ្ញុំបង្ហាញលិខិតពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ១៩៩៥ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩០ ហើយប្អូនឈ្មោះ សន ថាច បានយកពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ២៥០៨ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨៩ មកអះអាងវិញ។ ពេលនោះអាជ្ញាធរភូមិឃុំបានចេញលិខិតបញ្ជាក់លេខ: ២៧៧/១៩ ប ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ថា: ចំពោះដី និងផ្ទះដែលឈ្មោះ [redacted]សារី ហៅ[redacted]សារី ស្នាក់នៅបច្ចុប្បន្ន ដែលបានទៅធ្វើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីនោះ គឺម្តាយចែកឲ្យទៅកូនឈ្មោះ[redacted] ថាច ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ ដីធ្លី ស្របច្បាប់លេខ: ២៥០៨/ ក.អ.ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៨៩ ចេញដោយលោក [redacted] អឿន មេឃុំកោះអន្លង់ចិន និងបានទទួលពាក្យស្នើសុំកាន់កាប់ដីរបស់ឈ្មោះ [redacted]ថាច ដោយការិយាល័យភូមិបាលស្រុកស្អាងទៅវិញ។



Scanned with CamScanner

-អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទសូមរក្សាខ្លឹមសារពាក្យបណ្តឹងតប ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល។ សូមបញ្ជាក់ថា ដើមចោទបានអះអាងថា ឈ្មោះ [redacted] នឿន បានផ្ទេរដីទំនាស់ខាងលើនេះមកឱ្យខ្លួន ប៉ុន្តែមិនមានឯកសារណាមួយដែលបញ្ជាក់ផ្លូវការឡើយ ដែលនេះផ្ទុយទៅនឹង មាត្រា ១៣៣, មាត្រា ១៣៤, មាត្រា ១៣៥, មាត្រា ១៦០ និងមាត្រា ១៦២ នៃក្រមរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត លទ្ធកម្មកម្មសិទ្ធិរបស់ឈ្មោះ [redacted] ថាច ផ្ទុយនឹងមាត្រា ២៤៨ និងមាត្រា ២៤៩ នៃច្បាប់ភូមិបាល។ ចំណែកឯ ពាក្យសុំ ដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៩០ មេភូមិចេញលិខិតបញ្ជាក់អះអាងថា កូនក្តីខ្ញុំបានលួចធ្វើហើយបានធ្វើការមោឃៈ ទៅលើពាក្យសុំនោះ។ ត្រង់ចំណុចនេះដែរ ខ្ញុំសូមបញ្ជាក់ថា មេភូមិមិនមានសិទ្ធិអំណាចក្នុងការមោឃៈលិខិតពាក្យសុំ នោះទេ គឺមានតែអាជ្ញាធរតុលាការតែប៉ុណ្ណោះ។ ចំណែកឯដីចំនួន ០២ (ពីរ) កន្លែង ដែលមានក្នុងលិខិតប្រទានកម្ម នោះវិញ គឺជាអំណោយផ្តាច់ឱ្យកូនក្តីខ្ញុំ ដោយមិនមានការបញ្ជាក់ថា មានការដោះដូរដីនោះទេ។ ដីទំនាស់ខាងលើនេះ គឺមានសាក្សីជាច្រើនបញ្ជាក់ថា ជារបស់កូនក្តីខ្ញុំ។

**៦- ការអះអាងរបស់សាក្សី**

**៦-១. សាក្សីដើមចោទ៖**

-សាក្សីឈ្មោះ [redacted]**ណារី** បានឆ្លើយបញ្ជាក់ថា៖ មុនពេលម្តាយដើមចោទ និងចុងចម្លើយបានទទួលមរណៈភាព ខ្ញុំជាអ្នករស់នៅជាមួយ ដើម្បីមើលថែម្តាយរបស់ដើមចោទ និងចុងចម្លើយ។ ដីទំនាស់ខាងលើនេះ ដំបូងឡើយជាដីរបស់ ឈ្មោះ [redacted] នឿន ដែលកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ។ នៅថ្ងៃខែឆ្នាំមិនចាំ ឈ្មោះ [redacted] នឿន បានចែកឱ្យឈ្មោះ [redacted] ថាច។ ក្រោយពីឈ្មោះ [redacted] ថាច ទៅរស់នៅបរទេសឈ្មោះនេះបានផ្ញើប្រាក់ឱ្យឈ្មោះ [redacted] សារី ដែលរស់នៅ លើដីខាងលើនេះឱ្យធ្វើផ្ទះ។

-សាក្សីឈ្មោះ [redacted]**គឹមសត់** បានឆ្លើយបញ្ជាក់ថា៖ ខ្ញុំធ្លាប់រស់នៅជាមួយនឹងដើមចោទតាំងពីតូចៗ ប្រហែលអាយុ ១០ឆ្នាំ។ ដីទំនាស់ខាងលើនេះជារបស់ដើមចោទឈ្មោះ [redacted] ថាច។ ផ្ទះសព្វថ្ងៃនេះគឺពូ [redacted] ថាច គាត់ជាអ្នកផ្ញើប្រាក់ឱ្យ ឈ្មោះ [redacted] សារី ដើម្បីសង់ផ្ទះថ្មី។

-សាក្សីឈ្មោះ [redacted] **ផល្លា** បានឆ្លើយបញ្ជាក់ថា៖ ខ្ញុំជាប្អូនបង្កើតរបស់ឈ្មោះ [redacted] ថាច និងមិនដែលមាន ទំនាស់ជាមួយនឹងឈ្មោះ [redacted] សារី នោះទេ។ ផ្ទះខ្ញុំស្ថិតនៅចំងាយប្រហែល ០១គីឡូម៉ែត្រ ពីដីទំនាស់ខាងលើនេះ។ ដីទំនាស់ខាងលើនេះ ដំបូងឡើយជារបស់ឈ្មោះ [redacted] នឿន ហើយបានប្រគល់ឱ្យឈ្មោះ [redacted] ថាច តែម្នាក់គត់។ កាលដើមឡើយផ្ទះដែលនៅលើដីទំនាស់ខាងលើនេះ គឺជាផ្ទះឈើ ប៉ុន្តែឈ្មោះ [redacted] សារី និងឈ្មោះ [redacted] ថាច បានប្រាប់ខ្ញុំថា ផ្ទះសង់ថ្មីបច្ចុប្បន្នគឺឈ្មោះ [redacted] ថាច ជាអ្នកផ្ញើប្រាក់ឱ្យសង់។

-សាក្សីឈ្មោះ [redacted]**គឹមហួន** បានឆ្លើយបញ្ជាក់ថា៖ ដីទំនាស់ខាងលើនេះរដ្ឋបានចែកឱ្យឈ្មោះ [redacted] នឿន តាំងពី ឆ្នាំ១៩៧៩ មកម្ល៉េះ ហើយដីទំនាស់ជារបស់ឈ្មោះ [redacted] ថាច និងផ្ទះសព្វថ្ងៃសង់ដោយប្រើប្រាស់ប្រាក់របស់ឈ្មោះ [redacted] ថាច ដែលផ្ញើមកឱ្យឈ្មោះ [redacted] សារី ធ្វើការសាងសង់។

-សាក្សីឈ្មោះ [redacted]**ពេញ** បានឆ្លើយបញ្ជាក់ថា៖ ដីទំនាស់ពីដើមឡើយជារបស់ឈ្មោះ [redacted] នឿន ដែលត្រូវជា ម្តាយរបស់ដើមចោទ និងចុងចម្លើយ។ កាលពីថ្ងៃខែឆ្នាំមិនចាំ ឈ្មោះ [redacted] សារី បានប្រាប់ខ្ញុំថា ដីទំនាស់ខាងលើនេះ ជារបស់ឈ្មោះ [redacted] ថាច និងគេឱ្យប្រាក់មកសង់ផ្ទះថ្មីផងដែរ។

-សាក្សីឈ្មោះ [redacted] **ចាន្នី** បានឆ្លើយបញ្ជាក់ថា៖ ខ្ញុំជាប្អូនរបស់ឈ្មោះ [redacted] សារឿន។ បងប្រុសខ្ញុំបានប្រាប់ខ្ញុំថា ដីខាងលើនេះឈ្មោះ [redacted] នឿន បានចែកឱ្យឈ្មោះ [redacted] ថាច ហើយកាលពីមុនផ្ទះនៅលើដីទំនាស់នេះគឺជាផ្ទះឈើ ហើយឈ្មោះ [redacted] ថាច បានផ្ញើប្រាក់ឱ្យសង់ផ្ទះថ្មថ្មី។



Scanned with CamScanner

៦-២. សាក្សីចុងចម្លើយ៖

-សាក្សីឈ្មោះ [redacted] សុគន្ធ បានឆ្លើយបញ្ជាក់ថា៖ ខ្ញុំត្រូវជាបងប្អូនជីដូនមួយរបស់ដើមចោទ និងចុងចម្លើយ។ ដីនេះជារបស់ឈ្មោះ [redacted] នឿន តាំងពីឆ្នាំ១៩៧៩។ ខ្ញុំមិនបានដឹងថា ដីនេះឈ្មោះ [redacted] នឿន បានប្រគល់ឱ្យនរណាទេ។

-សាក្សីឈ្មោះ [redacted] វុន បានឆ្លើយបញ្ជាក់ថា៖ ដីទំនាស់ខាងលើនេះ ដំបូងឡើយជារបស់ឈ្មោះ [redacted] នឿន។ ពាក្យសុំកាន់កាប់ដែលធ្វើឡើងក្នុងឆ្នាំ១៩៩០ គឺខ្ញុំមិនបានដឹងទេគ្រាន់តែឃើញថា ឈ្មោះ [redacted] សារី រស់នៅលើដីទំនាស់នេះរហូត និងបានធ្វើការជួសជុលផ្ទះ ប៉ុន្តែមិនដឹងថាបានប្រាក់មកពីណានោះទេ។

**៧- អង្គហេតុដែលគ្មានវិវាទ៖**

-ដើមចោទបានបញ្ជាក់ថា ដីទំហំ ១.៦១៦ ម៉ែត្រការ៉េ ដើមឡើយជាដីរបស់ម្តាយឈ្មោះ [redacted] នឿន មានខ្លួន និងបងស្រីឈ្មោះ [redacted] សារី ហៅ [redacted] សារី រស់នៅតាំងពីឆ្នាំ១៩៧៩ ចុងចម្លើយទទួលស្គាល់។

**៨- អង្គហេតុដែលមានវិវាទ៖**

**១. ដើមចោទបានអះអាងថា** ចុងចម្លើយលួចធ្វើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ១៩៩៥ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩០ **ចុងចម្លើយអះអាងថា** ម្តាយឈ្មោះ [redacted] នឿន ជាអ្នកឱ្យខ្លួនទៅធ្វើ។

**២. ដើមចោទបានអះអាងថា** ម្តាយបានប្រគល់ដីឱ្យខ្លួននៅឆ្នាំ១៩៩៩ ហើយខ្លួនបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ហើយម្តាយឈ្មោះ [redacted] នឿន បានទិញដីដោះដូរចំនួន ០២ (ពីរ) កន្លែង ឱ្យទៅចុងចម្លើយរួចហើយ។ **ចុងចម្លើយមិនទទួលស្គាល់ទេ ដោយអះអាងថា** ខ្លួនមិនបានដឹងថាម្តាយប្រគល់ឱ្យដើមចោទទេ ហើយមិនទទួលបានចំណែកដីដែលម្តាយទិញមកដើម្បីដោះដូរទេ។

**៣. ដើមចោទអះអាងថា** ផ្ទះនៅលើដីទំនាស់នេះ ខ្លួនបានចំណាយលុយមកសង់ផ្ទះឱ្យបងស្រីស្នាក់នៅ។ **ចុងចម្លើយអះអាងថា** ផ្ទះចាស់បានខូចខាតទៅក៏បានសាងសង់ផ្ទះថ្មីបានទទួលប្រាក់មកចំនួន ២៥០០$ (ពីរពាន់ប្រាំរយដុល្លាអាមេរិច) ពីឈ្មោះ [redacted] ថាច និងលុយចំណែកខ្លួនចំនួន ៥៥០០$ (ប្រាំពាន់ប្រាំរយដុល្លាអាមេរិច) ខ្លួនក៏បានចាក់ដីបំពេញបន្ថែមពីខាងមុខដែរ។

៩- ចំណុចវិវាទ៖

-តើអចលនវត្ថុផ្ទះ និងដីទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ ដែលមានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] វុន មានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ដើមចោទ ឬ ចុងចម្លើយ ជាម្ចាស់កម្មសិទ្ធិ?

-តើការទាមទារសំណងការខូចខាត សេវាកម្មច្បាប់ និងសំណងជម្ងឺចិត្តចំនួន ៥០.០០០$ (ប្រាំម៉ឺនដុល្លារអាមេរិច) ត្រឹមត្រូវតាមច្បាប់ដែរឬទេ?

**១០- ភស្តុតាងដែលដើមចោទដាក់ជូនតុលាការពិនិត្យរួមមាន៖**

**១០-១. ភស្តុតាងជាឯកសារ៖**

-បង្កាន់ដៃទទួលពាក្យលេខ ០៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ទទួលស្គាល់ដោយលោក ម៉ៅ អឿន មេឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នក្រុងតាខ្មៅ ខេត្តកណ្តាល)។

-លិខិតបញ្ជាក់លេខ ២៧៧/១៩ ប ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ទទួលស្គាល់ដោយលោកចៅសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

-កិច្ចសន្យាប្រទានកម្មដីពីម្តាយឈ្មោះ [redacted] នឿន ទៅឱ្យកូនឈ្មោះ [redacted] សារី ហៅសន សារី ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩។

-បង្កាន់ដៃស្នើសុំចុះបញ្ជីលេខ ០៨១១០៨០២០៣១៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩។



Scanned with CamScanner

១០-២. ភស្តុតាងជាសាក្សី៖

-សាក្សីឈ្មោះ [redacted] ណារី ភេទស្រី អាយុ៦៣ឆ្នាំ សញ្ជាតិខ្មែរ

-សាក្សីឈ្មោះ [redacted] គីមសត់ ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ

-សាក្សីឈ្មោះ [redacted] គីមហួន ភេទប្រុស អាយុ៧២ឆ្នាំ សញ្ជាតិខ្មែរ

-សាក្សីឈ្មោះ [redacted] ពេញ ភេទស្រី អាយុ៧៩ឆ្នាំ សញ្ជាតិខ្មែរ

-សាក្សីឈ្មោះ [redacted] ចាន្ទី ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ

អ្នកទាំងអស់គ្នាមានទីលំនៅបច្ចុប្បន្នភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល។

១១- ភស្តុតាងដែលសហចុងចម្លើយដាក់ជូនតុលាការពិនិត្យរួមមាន៖

១១-១. ភស្តុតាងជាឯកសារ៖

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០។

-បង្កាន់ដៃទទួលពាក្យរបស់ឈ្មោះ [redacted] ណារី ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩០។

-សំណើសុំទប់ស្កាត់ការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២។

-សំណើស្នើសុំសេចក្ដីអន្តរាគមន៍។

១១-២. ភស្តុតាងជាសាក្សី៖

-សាក្សីឈ្មោះ [redacted] សុគន្ធ ភេទស្រី អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ

-សាក្សីឈ្មោះ [redacted] រុន ភេទស្រី អាយុ៨០ឆ្នាំ សញ្ជាតិខ្មែរ

អ្នកទាំងពីរមានទីលំនៅបច្ចុប្បន្នភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល។

## សំអាងហេតុ

**ឆ្លងតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងនានា ឃើញថា៖**

១- តាមការពិនិត្យទៅលើពាក្យបណ្ដឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងពាក្យបណ្ដឹងតប ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ របស់សហចុងចម្លើយ ឃើញថាមានលក្ខណៈត្រឹមត្រូវស្របតាមមាត្រា **៧៥ កថាខណ្ឌទី២** និងមាត្រា **៩ ចំណុច ឆ** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**២- តាមការពិនិត្យទៅលើសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ឃើញថា:** ដីដែលជាកម្មវត្ថុនៃវិវាទខាងលើនេះ មានទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted] រុន មានទីតាំងស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលកាលពីដើមឡើយជាដីរបស់ឈ្មោះ [redacted] នឿន ត្រូវជាម្ដាយរបស់ដើមចោទ កាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ។ ក្រោយមកឈ្មោះ [redacted] នឿន បានធ្វើប្រទានកម្មដីទំនាស់ខាងលើនេះមកឱ្យដើមចោទ ហើយដើមចោទបានធ្វើពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៥០៨ កអច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ដែលចេញដោយមេឃុំកោះអន្លង់ចិន។ ក្រោយមកដោយសារចុងចម្លើយឈ្មោះ [redacted] សារី មិនមានកន្លែងស្នាក់នៅ ក៏ដើមចោទបានអនុញ្ញាតឱ្យចុងចម្លើយស្នាក់នៅទីតាំងដីទំនាស់ខាងលើនេះជាបណ្ដោះអាសន្ន។ **ប៉ុន្តែផ្អែកតាមការពិនិត្យទៅលើសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ និងអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយវិញ ឃើញថា:** នៅអំឡុងឆ្នាំ១៩៩០ ចុងចម្លើយបានកាន់កាប់ដីដែលមានទីតាំងខាងលើនេះ ដោយមានពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០។ **តុលាការពិចារណាឃើញថា** ពិតជាមានអត្ថិភាពនៃអង្គហេតុប្រទានកម្មដីខាងលើនេះមកឱ្យដើមចោទ និងការណ៍ដែលដើមចោទអនុញ្ញាតឱ្យចុងចម្លើយរស់នៅលើដីដែលជាកម្មសិទ្ធិ



Scanned with CamScanner

របស់ដើមចោទប្រាកដមែន ដោយមូលហេតុថា តាមការពិនិត្យទៅលើការឆ្លើយបញ្ជាក់របស់សាក្សីឈ្មោះ [redacted] ណារី, ឈ្មោះ [redacted] គីមសត់, ឈ្មោះ [redacted] គីមហួន, ឈ្មោះ [redacted] ពេញ និងឈ្មោះ [redacted] ចាន់ធី បានអះអាងប្រហាក់ប្រហែលគ្នាថា ដីដែលជាកម្មវត្ថុនៃវិវាទខាងលើនេះជាដីដែលឈ្មោះ [redacted] នឿន បានធ្វើប្រទានកម្មមកឱ្យដើមចោទ ហើយដើមចោទបានអនុញ្ញាតឱ្យចុងចម្លើយស្នាក់អាស្រ័យជាបណ្តោះអាសន្ន ហើយថែមទាំងបានផ្ញើប្រាក់ឱ្យចុងចម្លើយសាងសង់ផ្ទះថ្មី ដែលកាលពីមុនជាផ្ទះឈើតែប៉ុណ្ណោះ។ តាមរយៈនេះបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] ថាច ពិតជាកម្មសិទ្ធិករលើដី និងផ្ទះ ដែលជាកម្មវត្ថុនៃវិវាទខាងលើនេះប្រាកដមែន។

៣- តាមការពិនិត្យទៅលើពាក្យបណ្តឹងតប ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ និងសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ ឃើញថា អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានអះអាងថា: ដីទំនាស់ខាងលើនេះ គឺជាកម្មសិទ្ធិរបស់ចុងចម្លើយ ដោយផ្អែកទៅលើពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ ហើយបានកាន់កាប់តាំងពីឆ្នាំ១៩៩០ រហូតដល់បច្ចុប្បន្ននេះ។ ចំណែកឯពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៥០៨ កអច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ដែលបញ្ជាក់ថា ដើមចោទជាកម្មសិទ្ធិលើដីទំនាស់ខាងលើនេះ គឺមិនពិតប្រាកដទេ។

-បើពិនិត្យទៅលើពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ និងសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ អះអាងថា: ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ របស់ចុងចម្លើយឈ្មោះ [redacted] សារី គឺចុងចម្លើយឈ្មោះ [redacted] សារី បានធ្វើដោយមិនបានឱ្យឈ្មោះ [redacted] នឿន ជាម្តាយបានដឹងទេ។ ឈ្មោះ [redacted] នឿន បានធ្វើប្រទានកម្មដីទំនាស់ខាងលើនេះមកឱ្យដើមចោទឈ្មោះ [redacted] ថាច ដោយមានពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ២៥០៨ កអច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ដោយផ្អែកទៅលើលិខិតបញ្ជាក់លេខ ២៧៧/១៩ ប ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ដែលចេញដោយចៅសង្កាត់កោះអន្លង់ចិន រួចហើយ។

**ចំណុចនេះតុលាការពិចារណាឃើញថា** ពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ១៩៩៥ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩០ របស់ចុងចម្លើយឈ្មោះ [redacted] សារី ពិតជាធ្វើឡើងដោយវិការៈ ដោយមូលហេតុថា ចុងចម្លើយឈ្មោះ [redacted] សារី បានលួចធ្វើលិខិតនេះដោយគ្មានការយល់ព្រមពីឈ្មោះ [redacted] នឿន ត្រូវជាម្តាយ ប្រាកដមែន ដោយយោងទៅលើលិខិតបញ្ជាក់លេខ ២៧៧/១៩ ប ជ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ដែលបានចេញដោយចៅសង្កាត់កោះអន្លង់ចិន។

៤-តាមការពិនិត្យទៅលើពាក្យបណ្តឹងតប ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣និងសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងចុងចម្លើយ អះអាងថា: មិនមានការដោះដូរដីទំនាស់ឱ្យដើមចោទ និងដីចំនួន ០២(ពីរ)កន្លែងឱ្យចុងចម្លើយនោះទេ។ ប៉ុន្តែអ្នកតំណាងដោយអាណត្តិឱ្យដើមចោទបានលើកឡើងថា ដោយសារតែមិនចង់ឱ្យដើមចោទ និងចុងចម្លើយឈ្លោះគ្នាទើបឈ្មោះ [redacted] នឿន បានទិញដីចំនួនពីរកន្លែងពីឈ្មោះ [redacted] វង់ ឱ្យចុងចម្លើយ។ **តុលាការពិចារណាឃើញថា** ពិតជាមានអត្ថិភាពនៃអង្គហេតុប្រទានកម្មដីទំនាស់ឱ្យដើមចោទ និងដីចំនួន ០២ (ពីរ) កន្លែងដែលទិញពីឈ្មោះ [redacted] វង់ ឱ្យចុងចម្លើយប្រាកដមែន ដោយមូលហេតុថា តាមការពិនិត្យទៅលើលិខិតបញ្ជាក់ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៩ ដែលចេញដោយមេភូមិកណ្តាលកោះ និងកិច្ចសន្យាផ្ទេរមរតកឱ្យកូន ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ឃើញថា ឈ្មោះ [redacted] នឿន ពិតជាបានធ្វើប្រទានដីចំនួន ០២ (ពីរ) កន្លែង ឱ្យចុងចម្លើយ និងដីដែលជាកម្មវត្ថុនៃវិវាទខាងលើមកឱ្យដើមចោទឈ្មោះ [redacted] ថាច ប្រាកដមែន។ ហើយម្យ៉ាងវិញទៀត តាមការពិនិត្យទៅលើអំឡុងពេលនៃការធ្វើកិច្ចសន្យាផ្ទេរមរតកឱ្យកូន ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ និងពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ ឃើញថា មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែលដើមចោទបានលើកឡើង ដែលបញ្ជាក់បានថា ពិតជាមានអត្ថិភាពនៃអង្គហេតុប្រទានកម្មរវាងឈ្មោះ [redacted] នឿន និងដើមចោទ ហើយនិងរវាងឈ្មោះ [redacted] នឿន និងចុងចម្លើយប្រាកដមែន។ ត្រង់ចំណុចនេះបញ្ជាក់បានថា ដើមចោទពិតជាកម្មសិទ្ធិករនៃដីដែលជាកម្មវត្ថុនៃវិវាទខាងលើនេះប្រាកដមែន។



Scanned with CamScanner

៥- តាមការពិនិត្យទៅលើពាក្យសុំកាន់កាប់ដីធ្លីលេខ ២៥០៨ ក អ ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ និងបង្កាន់ដៃទទួលពាក្យលេខ ០៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ឃើញថា ដើមចោទបានធ្វើការស្នើសុំកាន់កាប់ដីធ្លីខាងលើ តាមរយៈពាក្យសុំកាន់កាប់ដីធ្លីលេខ ២៥០៨ កអច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៩ និងបានទទួលពាក្យស្នើសុំនេះដោយការិយាល័យភូមិបាលស្រុកស្អាងផងដែរ តាមរយៈបង្កាន់ដៃទទួលពាក្យលេខ ០៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ហើយមន្ត្រីជំនាញសុរិយោដីបានធ្វើការពិនិត្យឯកសារ ចុះវាស់វែងដីធ្លី និងបានចេញបង្កាន់ដៃលេខ ០៨១១០៨០២០៥៤៥ មានក្បាលដីលេខ ០៣១៨ រួចហើយ ពេលនោះចុងចម្លើយមិនបានជំទាស់ទេ។ នៅពេលដែលដើមចោទត្រឡប់ទៅប្រទេសបារាំងវិញ ចុងចម្លើយបានប្ដឹងជំទាស់មកសុរិយោដីធ្វើឱ្យដើមចោទមិនទទួលបាននូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។ **តុលាការពិចារណាឃើញថា** លទ្ធកម្មកម្មសិទ្ធិដោយប្រទានកម្មរបស់ដើមចោទត្រឹមត្រូវតាមច្បាប់ និងបានបំពេញលក្ខខណ្ឌបង្កើតអានុភាព និងលក្ខខណ្ឌតតាំងនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុផងដែរ ដោយស្របតាមមាត្រា **១៣៤ កថាខណ្ឌទី១** និងមាត្រា **១៣៥** នៃក្រមរដ្ឋប្បវេណី។ ត្រង់ចំណុចនេះមានន័យថា ដើមចោទឈ្មោះ [redacted]ថាច ពិតជាកម្មសិទ្ធិករនៃដីដែលជាកម្មវត្ថុនៃវិវាទ ដែលមានទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ [redacted] សាខន ខាងលិចទល់នឹងឈ្មោះ [redacted]រុន និងមានទីតាំងស្ថិតនៅភូមិកណ្ដាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល(បង្កាន់ដៃលេខ ០៨១១០៨០២០៥៤៥ ក្បាលដីលេខ ០៣១៨) ប្រាកដមែន ដោយអនុលោមតាមមាត្រា **១៣៤ កថាខណ្ឌទី១**, មាត្រា **១៣៥** និងមាត្រា **១៣៧** នៃក្រមរដ្ឋប្បវេណី។

៦- តាមការពិនិត្យទៅលើពាក្យបណ្ដឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ និងសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ឃើញថា បច្ចុប្បន្នកម្មវត្ថុនៃវិវាទខាងលើនេះ ត្រូវបានកាន់កាប់ និងស្នាក់ដោយចុងចម្លើយ។ ត្រង់ចំណុចនេះដែរ ដោយសារតែដើមចោទជាកម្មសិទ្ធិករនៃដីដែលជាកម្មវត្ថុនៃវិវាទខាងលើនេះ ហេតុដូច្នេះ ដើមចោទមានសិទ្ធិទាមទារឱ្យចុងចម្លើយប្រគល់វិញនូវដីខាងលើនេះមកឱ្យខ្លួនវិញ ដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ ដោយអនុលោមតាមមាត្រា **១៥៥** នៃក្រមរដ្ឋប្បវេណី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យចុងចម្លើយប្រគល់ដីដែលជាកម្មវត្ថុនៃវិវាទខាងលើនេះ ឱ្យទៅដើមចោទតាមការទាមទាររបស់ដើមចោទ។

៧- ការទាមទាររបស់សហចុងចម្លើយ ដូចមាននៅក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃ១៧ ខែមីនា ឆ្នាំ២០២៣ **តុលាការពិចារណាឃើញថា** មិនមានមូលហេតុត្រឹមត្រូវតាមច្បាប់នោះទេ ដោយផ្អែកទៅលើ **ចំណុចទី២ រហូតដល់ចំណុចទី៥** នៃសំអាងហេតុ និងភស្ដុតាងនានាដែលតុលាការបានពិនិត្យ។ ហេតុដូច្នេះ គប្បីតុលាការច្រានចោលការទាមទាររបស់ចុងចម្លើយ។

៨- តាមការពិនិត្យទៅលើពាក្យបណ្ដឹង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ និងសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ឃើញថា ទង្វើរបស់សហចុងចម្លើយបានធ្វើឱ្យដើមចោទខាតបង់ពេលវេលា និងប៉ះពាល់ដល់កម្មសិទ្ធិស្របច្បាប់របស់ដើមចោទ។ ត្រង់ចំណុចនេះ ដើមចោទទាមទារឱ្យចុងចម្លើយសងសំណងការខូចខាត សេវាកម្មច្បាប់ និងសំណងជម្ងឺចិត្តចំនួន ៥០០០០$ (ប្រាំម៉ឺនដុល្លារអាមេរិច)។ **តុលាការយល់ឃើញថា** ពិតជាអត្ថិភាពនៃការខូចខាតផ្សេងៗកើតឡើងចំពោះដើមចោទប្រាកដមែន ប៉ុន្តែដើមចោទមិនបានដាក់ភស្ដុតាងទាក់ទងទៅនឹងឯកសារចំណាយផ្សេងៗ និងកម្រិតនៃការខូចខាតរបស់ខ្លួនមកកាន់តុលាការពិនិត្យឡើយ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចអំពីសំណងការខូចខាត សេវាកម្មច្បាប់ និងសំណងជម្ងឺចិត្ត តាមតថភាពជាក់ស្ដែងដោយផ្អែកទៅលើមាត្រា **៧៤៣** នៃក្រមរដ្ឋប្បវេណី។

៩- ដោយអនុលោមតាមមាត្រា **៦៤ កថាខណ្ឌទី១** នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យចុងចម្លើយទទួលបន្ទុកនៃប្រាក់ប្រដាប់ក្ដី។



Scanned with CamScanner

# សេចក្តីសម្រេចបញ្ចប់

១- បញ្ជាក់ថា៖ ដើមចោទឈ្មោះ[redacted]ថាច ជាកម្មសិទ្ធិករលើអចលនវត្ថុផ្ទះ និងដីទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ[redacted]សាខន ខាងលិចទល់នឹងឈ្មោះ[redacted]រុន និងមានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល (បង្កាន់ដៃលេខ ០៨១១០៨០២០៥៤៥ មានក្បាលដីលេខ ០៣១៨)។

២- បង្គាប់ឱ្យចុងចម្លើយឈ្មោះ[redacted]សារី ហៅ[redacted]សារី និងប្តីឈ្មោះ[redacted]សាវឿន ប្រគល់អចលនវត្ថុផ្ទះ និងដីទំហំ ១.៦១៦ (មួយពាន់ប្រាំមួយរយដប់ប្រាំមួយ) ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងឈ្មោះ[redacted]សាខន ខាងលិចទល់នឹងឈ្មោះ[redacted]រុន មានទីតាំងស្ថិតនៅភូមិកណ្តាលកោះ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល (បង្កាន់ដៃលេខ ០៨១១០៨០២០៥៤៥ មានក្បាលដីលេខ ០៣១៨) ឱ្យមកដើមចោទឈ្មោះ[redacted]ថាច។

៣- បង្គាប់ឱ្យចុងចម្លើយឈ្មោះ[redacted]សារី ហៅ[redacted]សារី និងប្តីឈ្មោះ[redacted]សាវឿន សងសំណងការខូចខាត និងសំណងជម្ងឺចិត្ត ចំនួន ២០,០០០,០០០៛ (ម្ភៃលានរៀល) ឱ្យដើមចោទឈ្មោះ [redacted] ថាច។ បណ្តឹងទាមទារលើសពីនេះច្រានចោល។

៤- ច្រានចោលពាក្យបណ្តឹងតប ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ របស់ចុងចម្លើយឈ្មោះ [redacted] សារី ហៅ[redacted]សារី និងប្តីឈ្មោះ[redacted]សាវឿន។

៥- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

-សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ ចំពោះមុខអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ, អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១៣រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

កណ្តាល, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner